ព្រះរាជាណាចក្រកម្ពុជា

ស្ថានឯកអគ្គរាជទូតកម្ពុជា
ប្រចាំចក្រភពអង់គ្លេស

ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីជូនដំណឹង

ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំចក្រភពអង់គ្លេស សូមជម្រាបជូនដំណឹងដល់ប្រជាពលរដ្ឋខ្មែរ សិស្ស និងនិស្សិត ដែលកំពុងរស់នៅក្នុងចក្រភពអង់គ្លេសឱ្យបានជ្រាបថា ប្រឈមនឹងការរីករាលដាលនៃការឆ្លងកូវីដ-១៩ ដែលកំពុងរាតត្បាតនៅទូទាំងពិភពលោក នៅក្នុងបណ្តាប្រទេសអឺរ៉ុប និងជាពិសេសនៅក្នុងចក្រភពអង់គ្លេស កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ រដ្ឋាភិបាលអង់គ្លេសបានចេញនូវវិធានការចាំបាច់ និងតឹងរឹងមួយចំនួន ដើម្បីទប់ស្កាត់ការឆ្លងកូវីដ-១៩ ដូចខាងក្រោម៖

-ចាប់ពីយប់ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ តទៅប្រជាពលរដ្ឋអង់គ្លេសនឹងត្រូវបានអនុញ្ញាតិឱ្យចេញពីផ្ទះរបស់ខ្លួនបានតែក្នុងគោលបំណង ដើម្បីទៅទិញវត្ថុចាំបាច់មួយចំនួន តម្រូវការចាំបាច់ទាក់ទងផ្នែកពេទ្យ ការទៅ-មកធ្វើការ តែក្នុងករណីចាំបាច់បំផុត។

-ការទៅទិញម្ហូបអាហារ និងថ្នាំពេទ្យត្រូវទិញតិចតួច តាមដែលអាចធ្វើទៅបាន។

-ហាងលក់ទំនិញមិនចាំបាច់ចំពោះមុខដូចជា ហាងលក់សំលៀកបំពាក់ គ្រឿងអេឡិចត្រូនិកនានាតម្រូវឱ្យបិទ។

-បណ្ណាល័យ កន្លែងលេងកំសាន្ត កន្លែងហាត់ប្រាណនៅខាងក្រៅ និងកន្លែងគោរពបូជានានាតម្រូវឱ្យបិទ។

-ហាមឃាត់ការជួបជុំគ្នាលើសពីចំនួន២នាក់ឡើងទៅនៅទីសាធារណៈ លើកលែងតែអ្នករស់នៅជាមួយគ្នា។

-ហាមឃាត់ការរៀបចំព្រឹត្តិការណ៍សង្គមទាំងឡាយរាប់បញ្ចូលទាំងពិធីរៀបអាពាហ៍ពិពាហ៍ និងការធ្វើពិធី Baptism (តាមគ្រឹស្តសាសនា)។

-ពិធីបុណ្យសពពុំបានត្រូវរាប់បញ្ចូលក្នុងការរឹតបន្តឹងនេះទេ។

-សួនឧទ្យាននានាបើកសម្រាប់តែការធ្វើលំហាត់ប្រាណ ប៉ុន្តែហាមឃាត់ការជួបជុំគ្នា។

-ត្រូវស្ថិតនៅធ្វើកាងារ និងរៀនសូត្រនៅក្នុងផ្ទះ ប្រសិនជាអាចធ្វើបាន។

-ចៀសវាងការប្រមូលផ្តុំជាមួយមិត្តភក្តិ និងក្រុមគ្រួសារ។ ត្រូវធ្វើការប្រាស្រ័យទាក់ទងគ្នាតាមរយៈទូរស័ព្ទ អ៊ីនធឺណែត និងប្រព័ន្ធផ្សព្វផ្សាយសង្គម។

-ប៉ូលីសអាចនឹងចាប់បង្ខំដោយការពិន័យជាប្រាក់ ចំពោះអ្នកមិនគោរពតាមវិធានការ និងបទបញ្ជារទាំងនេះ។

64 Brondesbury Park, Willesden Green, London NW6 7AT, Tel: +44 20 8451 7850, Fax: +44 20 8451 7594
Email: cambodianembassy@btconnect.com Website: www.cambodianembassy.org.uk

វិធានការរឹតបន្តឹងទាំងនេះមានរយៈពេលបីសប្តាហ៍ បន្ទាប់មកវិធានការរឹតបន្តឹងទាំងនេះនឹងត្រូវធ្វើការត្រួតពិនិត្យឡើងវិញដោយផ្អែកលើលទ្ធផលនៃការអនុវត្តន៍។

★ក្នុងករណីមានសុខភាពខុសប្រក្រតី ដែលសង្ស័យពាក់ព័ន្ធនឹងកូវីដ-១៩ សូមទំនាក់ទំនងតាមទូរស័ព្ទទៅ NHS ១១១ ។

★ក្នុងករណីចាំបាច់ និងបន្ទាន់ បងប្អូន សិស្ស និងនិស្សិតអាចទំនាក់ទំនងមកមន្ត្រីស្ថានទូតតាមរយៈលេខទូរស័ព្ទ +44 (0) 7 414 132 678 ឬ +44 (0) 7 366 686 843។

សូមបងប្អូនប្រជាពលរដ្ឋ សិស្ស និងនិស្សិតទាំងអស់មេត្តាយកចិត្តទុកដាក់អនុវត្តវិធានការ និងបទបញ្ញារឹតបន្តឹងខាងលើរបស់រដ្ឋាភិបាលអង់គ្លេស និងសូមប្រុងប្រយ័ត្នឱ្យបានខ្ពស់ក្នុងការការពារសុខភាពរបស់ខ្លួន។

ថ្ងៃអង្គារ ១កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

ទីក្រុងឡុងដ៍ ថ្ងៃទី ២៤ ខែមិនា ឆ្នាំ២០២០